# ដូសជំរុញនៃវ៉ាក់សាំង COVID-19

## សំណួរដែលត្រូវបានសួរញឹកញាប់

ខែមេសា ឆ្នាំ 2022

ដូសជំរុញគឺជាដូសវ៉ាក់សាំងបន្ថែម ដែលពង្រឹង (ជំរុញ) ការការពាររបស់អ្នក។

**ដូសជំរុញដំបូងអាចរកបានសម្រាប់៖**

- អ្នកដែលមានអាយុច្រើនជាង 12 ឆ្នាំ ដែលបានទទួលវ៉ាក់សាំង Pfizer ដូសទី 2 យ៉ាងហោចណាស់កាលពី 5 ខែមុន។
- អ្នកដែលមានអាយុច្រើនជាង 18 ឆ្នាំ ដែលបានទទួលវ៉ាក់សាំង Moderna ដូសទី 2 យ៉ាងហោចណាស់ 5 ខែមុន។
- អ្នកដែលមានអាយុច្រើនជាង 18 ឆ្នាំ ដែលបានទទួលវ៉ាក់សាំង J&J យ៉ាងហោចណាស់កាលពី 2 ខែមុន។

**ដូសជំរុញទីពីរអាចរកបានសម្រាប់៖**

- អ្នកដែលមានអាយុច្រើនជាង 50 ឆ្នាំ ដែលបានទទួលវ៉ាក់សាំងដូសជំរុញលើកទី 1 យ៉ាងហោចណាស់ 4 ខែមុន។
- អ្នកដែលមានអាយុច្រើនជាង 12 ឆ្នាំ ជាអ្នកដែលមានប្រព័ន្ធការពាររាងកាយចុះខ្សោយ និងបានទទួលវ៉ាក់សាំងដូចជំរុញលើកទី 1 យ៉ាងហោចណាស់ 4 ខែមុន។

- **តើការចាក់ដូសជំរុញមានន័យថាវ៉ាក់សាំងឥតប្រសិទ្ធភាពមែនទេ?**
  - គេរំពឹងថា វ៉ាក់សាំងមួយចំនួនបាត់បង់កម្លាំងតាមកាលវេលា ដូចជាវ៉ាស់សាំងតេតាណូសជាដើម ហើយមួយចំនួនទៀតត្រូវបានរចនាឡើងដើម្បីតម្រូវឱ្យមានការចាក់ដូសជំរុញជាប្រចាំ ដូចជាវ៉ាក់សាំងគ្រុនផ្តាសាយធំ។
  - យើងទាំងអស់គ្នាត្រូវការដូចជំរុញដើម្បីរក្សាការការពារឱ្យនៅមានទល់នឹងវីរុស COVID-19 ។
- **តើមនុស្សចាក់វ៉ាក់សាំងមិនទាន់គ្រប់គ្រាន់ទេឬ?**
  - អ្នករាល់គ្នាប្រឈមនឹងការធ្លាក់ខ្លួនឈឺ ឬសូម្បីតែបាត់បង់ជីវិតពី COVID-19 ប៉ុន្តែមនុស្សមានវ័យចំណាស់ និងអ្នកដែលមានលក្ខខណ្ឌសុខភាពមួយចំនួនគឺជាអ្នកដែលប្រឈមខ្លាំងជាង។ ដូសជំរុញបង្ការអ្នកមិនឱ្យឆ្លងវីរុស COVID-19 ហើយអាចជួយបង្ការមិនឱ្យអ្នកចម្លងវីរុសទៅដល់អ្នកដទៃ។
    - បុគ្គលដែលអ្នកអាចចម្លង COVID-19 ទៅដល់ឱ្យ អាចនឹងមិនមានសមត្ថភាពប្រយុទ្ធប្រឆាំងនឹងវីរុសបានល្អនោះទេ ហើយអាចនឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ឬចូលមន្ទីរពេទ្យ។
  - ជំងឺរាតត្បាតមិនទាន់បញ្ចប់នោះទេ ដូច្នេះចំនួនមនុស្សដែលមាន COVID-19 អាចកើនឡើងវិញម្តងទៀត។
- **ខ្ញុំកើតជំងឺ COVID-19 រួចហើយ។ តើខ្ញុំនៅតែត្រូវការចាក់វ៉ាក់សាំងដូសជំរុញដែរឬទេ?**
  - ត្រូវហើយ អ្នកអាចឆ្លង COVID-19 ច្រើនជាងម្តង ហើយអ្នកជំនាញមិនទាន់ដឹងនៅឡើយថា អ្នកមានការការពារយូរប៉ុនណានោះទេ ពីវីរុសបន្ទាប់ពីជាពីជំងឺ COVID-19 ហើយនោះ។
- **តើខ្ញុំអាចទៅចាក់វ៉ាក់សាំង ឬដូសជំរុញនៃវ៉ាក់សាំង COVID-19 ពីកន្លែងណា?**
  - ដូសជំរុញអាចរកបាននៅគ្រប់កន្លែងដែលផ្តល់ជូនការចាក់វ៉ាក់សាំង COVID-19 ។
  - សូមចូលមើល www.vaccines.gov ឬ www.phila.gov/vaccine ឬទូរសព្ទទៅ (215) 685-5488 ។
  - ប្រសិនបើមានការលំបាកក្នុងការទៅកាន់គ្លីនិក សូមចុះឈ្មោះក្នុង**កម្មវិធីចាក់វ៉ាក់សាំងតាមផ្ទះ** សម្រាប់អ្នក និងអ្នកផ្តល់ការថែទាំរបស់អ្នក៖ https://bit.ly/homeboundvaccinephl
- **តើគ្លីនិករបស់អ្នកអាចចូលប្រើបានដោយជនពិការដែរឬទេ? ចុះប្រសិនបើខ្ញុំនិយាយភាសាអង់គ្លេសមិនបានវិញ ឬត្រូវការមធ្យោបាយធ្វើដំណើរ?**
  - គ្លីនិកវ៉ាក់សាំង PDPH ទាំងអស់មានការបកប្រែផ្ទាល់មាត់តាមទូរសព្ទ អាចចូលបានដោយជនពិការ និងមានមធ្យោបាយធ្វើដំណើរដល់កន្លែងដោយមិនគិតថ្លៃ។ សូមចូលមើលនៅ https://bit.ly/KnowB4Ugo ឬទូរសព្ទទៅលេខ (215) 586-3006 ។
- **តើខ្ញុំអាចទទួលបានកាតវ៉ាក់សាំង COVID-19 ជំនួសវិញដោយរបៀបណា?**
  - ស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាវ៉ាក់សាំងរបស់អ្នក ដែលអាចយកប្រើបានជំនួសឱ្យកាតវ៉ាក់សាំង។
  - សូមចូលមើល https://bit.ly/LostVaxCardPHL ឬទូរសព្ទទៅលេខ (215) 685-5488 ចុចលេខ #5 សម្រាប់ការបកប្រែផ្ទាល់មាត់។